# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជានៅដុនបូស្កូកែប
# ថ្ងៃទី២៣ ឧសភា ២០១៧

អត្ថបទទី១៖ កក ១៦,២២-៣៤
ដំណឹងល្អ៖ យហ ១៦,៥-១១

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះគម្ពីរដែលយើងបានស្តាប់ ជាសញ្ញាសម្គាល់ដំបូងបង្អស់របស់ព្រះយេស៊ូ ជាលើកទីមួយដែលព្រះយេស៊ូបង្ហាញខ្លួន ជាលើកទីមួយដែលព្រះយេស៊ូបង្ហាញសញ្ញាសម្គាល់ដល់ប្រជាជនដែលមិនស្គាល់ព្រះអង្គ។ ព្រះយេស៊ូបានកើតនៅភូមិមេថ្លេហឹម ហើយរស់នៅក្នុងភូមិណាសារ៉ែតរហូតដល់៣០ឆ្នាំ។ ថ្ងៃនេះយើងស្តាប់គម្ពីរមួយយ៉ាងពិសេស ព្រះយេស៊ូបានកែប្រែទឹកទៅជាស្រាទំពាំងបាយជូរ លើកទីមួយដែលព្រះយេស៊ូបង្ហាញខ្លួនទៅមហាជន ព្រះយេស៊ូទៅចូលរួមពិធីអាពាហ៍ពិពាហ៍។ ហេតុនេះហើយ ព្រះយេស៊ូបានបង្ហាញខ្លួននៅកន្លែងដែលមនុស្សមានអំណរសប្បាយ ដោយសារពិធីអាពាហ៍ពិពាហ៍ ជាពេលវេលាដែលបងប្អូនឪពុកម្តាយទាំងសងខាង ជួបជុំគ្នាដោយអំណរសប្បាយ ដើម្បីអបអរសាទរគូស្វាមីភរិយាថ្មី។ ព្រះអង្គបានសម្រេចចិត្តធ្វើសញ្ញាមួយពិសេស ឲ្យពិធីអាពាហ៍ពិពាហ៍នោះសប្បាយថែមទៀត ដោយបានដូរទឹកទៅជាស្រាទំពាំងបាយជូរពិសេស។

ថ្ងៃនេះព្រះយេស៊ូណែនាំឲ្យយើង ធ្វើជាមនុស្សមានអំណរសប្បាយ មានសេចក្តីសុខសាន្ត ជាមូលដែលក្នុងសញ្ញាសម្គាល់ទីមួយរបស់ព្រះអង្គ គឺចង់ឲ្យមនុស្សយើងមានអំណរសប្បាយនិងសេចក្តីសុខសាន្ត។ ព្រះយេស៊ូចង់បង្ហាញឲ្យមហាជនថា ខ្ញុំមកដើម្បីឲ្យមនុស្សទាំងអស់មានសេចក្តីសុខ ដូចបងប្អូនមករៀននៅសាលាដុនបូស្កូកែបនេះ ដោយសារចង់មានអនាគតល្អ ដើម្បីមានជំនាញយ៉ាងច្បាស់លាស់។ បេលយើងមានការងារធ្វើច្បាស់លាស់ហើយ យើងកសាងគ្រួសារដោយមានសុភមង្គល នេះគឺយើងបានបំពេញគម្រោងការរបស់យើងផ្ទាល់។ ព្រះយេស៊ូយាងមក ដើម្បីជួយបំពេញគម្រោងការរបស់យើង ដើម្បីឲ្យយើងមានសេចក្តីសុខនិងសុភមង្គល ហេតុនេះហើយព្រះអង្គពិចារណាអំពីសេចក្តីត្រូវការរបស់មនុស្ស។ ថ្ងៃនេះតាមរយៈព្រះនាងម៉ារី ដែលបាននិយាយថា **បើលោកប្រាប់ឲ្យធ្វើអ្វីសូមធ្វើតាមលោកទៅ** ពេលនោះព្រះយេស៊ូបានឲ្យគេចាក់ទឹកក្នុងពាងហើយ

ព្រះអង្គដូរទឹកទៅជាស្រា គឺព្រះអង្គបានដឹងអំពីសេចក្តីត្រូវការរបស់គេ។ សម្រាប់យើងក៏ដូចគ្នាដែរ នៅក្នុងជីវិតរបស់យើងមានសេចក្តីត្រូវការ ដែលព្រះយេស៊ូនឹងយាងមកដើម្បីបំពេញសេចក្តីត្រូវការរបស់យើង។ នេះជាអត្ថន័យសម្រាប់ជីវិតរបស់យើងផ្ទាល់ យើងជាសិស្សសាលាកុំឲ្យយើងគិតតែយើងផ្ទាល់ខ្លួន តែឲ្យយើងចេះមើលសេចក្តីត្រូវការរបស់បងប្អូនយើងដែលរៀននៅសាលានេះ។ **យើងត្រូវបើកភ្នែក បើកត្រចៀក ដើម្បីមើលឃើញ ស្តាប់លឺសេចក្តីត្រូវការរបស់គេ** នឹងនៅថ្ងៃអនាគតយើងអាចមើលសេចក្តីត្រូវការរបស់សង្គមយើងដែរ។ មានខ្លះពេលគេមានគ្រួសារហើយ គេលាងគិតអំពីឪពុកម្តាយ បងប្អូន អ្នកជិតខាង និងអ្នកដទៃ តែសម្រាប់យើងឲ្យយើងចេះមើលសេចក្តីត្រូវការរបស់បងប្អូនយើងនៅក្នុងសាលា នឹងថ្ងៃអនាគតមើលខសេចក្តីត្រូវការរបស់សង្គមយើង។ សប្តាហ៍ក្រោយយើងនាំគ្នាទៅបោះឆ្នោត ដោយសារយើងជាប្រជាពលរដ្ឋដោយចេះមើលសេចក្តីត្រូវការរបស់សង្គមយើង។ នៅថ្ងៃអនាគតយើងធ្វើដូចម្តេច ដើម្បីឲ្យសង្គមរបស់យើងរីកចម្រើន? មិនមែនស៊ីសងតែលើអ្នកដឹកនាំ គឺអាស្រ័យលើយើងម្នាក់ៗ។ សម្រាប់សិស្សសាលាដុនបូស្កូទាំងអស់ក្នុងប្រទេសកម្ពុជា យើងមានឱកាសច្រើនដើម្បីរៀបចំខ្លួន ធ្វើជាសសរ ធ្វើជាពន្លឺសម្រាប់អ្នកដទៃក្នុងសង្គមនាថ្ងៃអនាគត។

បើលោកប្រាប់ឲ្យធ្វើអ្វីសូមធ្វើតាមលោកទៅ **គឺឲ្យយើងធ្វើជាអ្នកបម្រើ** ជាទូទៅមនុស្សយើងមិនចង់ធ្វើជាអ្នកបម្រើគេទេ យើងជួយគេលុះត្រាតែយើងទទួលបានផលប្រយោជន៍។ សម្រាប់ព្រះយេស៊ូ អង្គបានណែនាំឲ្យយើងគិតខ្ញុំជាអ្នកបម្រើ ដែលជួយអ្នកដទៃដោយមិនគិតផលប្រយោជន៍ ព្រះយេស៊ូបានណែនាំឲ្យយើងចេះគិតអំពីផលប្រយោជន៍រួម។ កុំឲ្យយើងរស់នៅក្នុងរបៀបអាត្មានិយម ដូចយើងមានពីកំណើតមក បន្តិចម្តងៗ ខ្ញុំជឿថាសង្គមយើងអាចទៅជាសង្គមថ្មី ប្រសិនបើយើងចេះគិតអំពីផលប្រយោជន៍រួម។ តែកុំឲ្យយើងចេះតែរិះគន់គេ មើលឃើញតែចំនុចអាក្រក់របស់គេ ឲ្យយើងមើលខ្លួនឯកសិន តើយើងបានគិតអំពីផលប្រយោជន៍រួមឬនៅ? ឬយើងគិតតែអំពីផលប្រយោជន៍ផ្ទាល់ខ្លួន?

ថ្ងៃនេះព្រះយេស៊ូបានណែនាំយើងយ៉ាងច្រើន ដោយយល់ថាព្រះយេស៊ូចង់ឲ្យយើងមានអំណរសប្បាយនឹងសេចក្តីសុខសាន្តអស់កាលជានិច្ច ដើម្បីបំពេញគម្រោងការរបស់ព្រះយេស៊ូនេះ គឺទីមួយឲ្យយើងចេះស្តាប់លឺសេចក្តីត្រូវការរបស់បងប្អូនឯទៀតៗ និងទីពីរ

ឲ្យយើងចេះបម្រើបងប្អូនឯទៀតៗ កុំឲ្យយើងគិតអំពីផលប្រយោជន៍ផ្ទាល់ខ្លួន គឺឲ្យយើងចេះគិតអំពីផលប្រយោជន៍រួម។ នេះបន្តិចម្តងៗ យើងអាចបង្កើតសេចក្តីសុខសាន្តយ៉ាងពិតប្រាកដដល់សង្គមរបស់យើង ឲ្យយើងទាំងអស់យល់ថា យើងជាគ្រួសារតែមួយដែលចេះស្រឡាញ់គ្នាទៅវិញទៅមកឲ្យយើងធ្វើជាពន្លឺសម្រាប់បងប្អូនឯទៀតៗ ឲ្យយើងធ្វើជាសេចក្តីស្រឡាញ់សម្រាប់បងប្អូនឯទៀតៗតាមរបៀបព្រះយេស៊ូ។ អាម៉ែន។